# អង្គរបុរី
## សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ អំពីលក្ខណៈបុគ្គលពាលនិងបុគ្គលបណ្ឌិត
## តាមអត្ថន័យរបស់ព្រះពុទ្ធសាសនានិងតាម
## ពាក្យចាស់បូរាណខ្មែរ

website : www.hoksavann.org

ថ្ងៃទី១៦ មេសា ២០០៧



បុគ្គលពាលគឺបុគ្គលដែលគ្មានដឹងបាបបុណ្យគុណទោសអ្វីឡើយ តែងតែប្រព្រឹត្តធ្វើអំពើអាក្រក់ ដោយកាយដោយវាចានិងដោយចិត្ត កាត់ប្រយោជន៍ខ្លួនឯងកាត់ប្រយោជន៍អ្នកដទៃ កាត់ប្រយោជន៍ជាតិនេះកាត់ប្រយោជន៍ជាតិខាងមុខ ជាពិសេសកាត់ប្រយោជន៍ព្រះនិព្វនទីរំលត់ទុក្ខ ។ ឯបុគ្គលជាបណ្ឌិតឬសប្បុរស មានលក្ខណៈផ្ទុយពីបុគ្គលពាល គឺបុគ្គលជាបណ្ឌិតតែងប្រព្រឹត្តអំពើល្អ ដោយកាយដោយវាចា និងដោយចិត្ត ផ្តល់សេចក្តីសុខដល់ខ្លួនលោកផងឲ្យអ្នកដទៃផង ។ តួយ៉ាងដូចព្រះសម្ពុទ្ធជាអគ្គបណ្ឌិត ព្រះអង្គកសាងខ្លួនព្រះអង្គឲ្យបានត្រាស់ជាព្រះពុទ្ធ បន្ទាប់មកព្រះអង្គទេសនាប្រោសព្រះញាតិនិងប្រោសមនុស្សសត្វជាទូទៅ ដែលមានឧបនិស្ស័យគួរឲ្យព្រះអង្គប្រោ-សបាន ។

ពាក្យចាស់បូរាណខ្មែរក៏មាននិយាយច្រើនអំពីលក្ខណៈបុគ្គលពាលនិងបុគ្គលបណ្ឌិតឬសប្បុរស ដូចពាក្យខ្លះតទៅនេះ ។ នៅជិតសប្បុរស សុខស្រួលទាំងអស់ឥតមានភិតភ័យ នៅជិតជនពាល មានតែទោសពៃរ៍ ទុក្ខព្រួយរាល់ថ្ងៃ មិនបានក្តីសុខ ។ នៅជិតជនពាល ដូចភ្លើងឆេះរាល ឆេះព្រៃព្រឹក្សា ដូចសត្វមានពិស ក្លាខ្លាំងអស្ចារ្យ បង្កទុក្ខា រាល់ពេលវេលា ។ ជនពាលសាមាន្យ ឃោរឃៅឈ្លានពាន មិនមានមេត្តា ជននោះតែងជួប នឹងទុក្ខទោសា ឈឺចាប់ខ្លោចផ្សា មិនដែលជៀសបាន ។ បាបពុំទាន់ឲ្យផលដល់កាលណា ពាលគិតថាបាបនោះដូចទឹកឃ្មុំ លុះបានកម្មឲ្យ

ផលដល់ប្រជុំ ទើបពាលរងទុក្ខធំដល់កាលនោះ ។ ព្រៃគ្មានសត្វជិត ប្រទេសគ្មានបណ្ឌិត ទ្វីបឥតសាសនា គ្រឹហាឥតបុត្រ ស្រុកគ្មានជាតិជា មេឃឥតចន្ទ្រា សូន្យចក្រវាឡ ។ គឺសំដៅយកទ្វីបលោក បើគ្មានសីលធម៌និងព្រះពុទ្ធសាសនាទេ ទ្វីបលោកនឹងត្រូវវិនាស ដោយសារគ្មានធម៌មេត្តា បៀតបៀនកាប់សម្លាប់គ្នា ។ កង្កែបនៅក្នុងអណ្ដូងទឹក ស្មានមេឃតូចនឹងប៉ុនគ្របឆ្នាំង បុគ្គលងងឹតល្ងង់អវិជ្ជាបាំង តែងតាំងខ្លួនថាប្រសើរឯក ។ ជាតិជាអ្នកជា ស្ងាត់ស្ងៀមកិរិយា មិនចេញក្អេងក្អាង ឯសន្ដានពាល ចេញឫសអាងយ៉ាង ភ្លាត់ស្នៀតច្រងាង ព្រោះព្រួសមិនឈប់ ។ ឈ្លោះនឹងពាលពិបាកបន្តិចហើយ កុំស្មានឡើយថាពាលស្ដាប់សព្ទវាចា ទុកជាវែកញែកខុសត្រូវទៅផ្លូវណា ក៏ពាលពោលថាគេមិនស្ដាប់ច្បាប់អ្វីទេ។ ទោសគេតូចឆ្មារថ្កោលថាជាធំ ទោសឯងប៉ុនភ្នំ ភ្នែកមើលពុំឃើញ ។ ទោសគេប៉ុនចៃ ឆ្អែបានជាធំ ទោសឯងប៉ុនភ្នំ ពុំយល់ថាទោស ។ ពាក្យបូរាណពោលឲ្យប្រយ័ត្នថា អ្វីដែលជាសត្រូវពីមុនមក ត្រូវលៃលកមើលឲ្យជាក់ការរាក់ជ្រៅ កុំប្រហែសធ្វេសជឿចិត្តមនុស្សឃោរឃៅ គំនុំចងជាប់នៅស្អិទ្ធឥតរសាយ ។ គុណទាំងឡាយទាំងអស់ ជារបស់មានក្នុងប្រាជ្ញ ឯទោសដូចអំណាច ជាធម្មជាតិមានក្នុងខ្លៅ ។ ពស់កាចមានពិសទោះវាខាំ ពេទ្យកែដោយថ្នាំអាចស្ងប់បាន មមុស្សកាចលើសពស់សាមាន្យ គ្មានអ្វីតែបានស្ងប់ស្ងាត់ឡើយ ។ វិស័យពេលថ្ងៃលំអអាទិត្យ ពេលយប់ងងឹតលំអចន្ទ្រា អំពើបាបលំអពួកពាលា កុសលធម្មាលំអពួកសប្បុរស ។ ណែនាំជនពាលឲ្យធ្វើល្អពាល មិនត្រេកអរប៉ុនចុងសក់ ពាលរីតបានចិត្តធ្វើអាក្រក់ ភូតភតកុហកថែមខ្លាំងក្លា ។ ប៉ុន្តែមានមនុស្សពាលខ្លះអាចកែខ្លួនធ្វើល្អ បន្ទាប់ពីបានស្ដាប់ពាក្យទូន្មានរបស់លោកអ្នកសប្បុរស ។ កូនប្រុសស្រីចូរចងចាំ បុរាណបានផ្ដាំផ្ដាច់ទុកថា ប្រដៅជនពាលដោយអាជ្ញា យុំយាំងប្រហារទើបវាខ្លាច ។ ប៉ុន្តែមានបុគ្គលពាលខ្លះ មិនបាច់ប្រើអាជ្ញា គ្រាន់តែណែនាំពន្យល់ប្រាប់ហេតុផលល្អអាក្រក់ ក៏ខ្លាចលែងហ៊ានធ្វើអា-ក្រក់ ។ មុននឹងធ្វើទារុណកម្មទៅលើគេ ត្រូវអ្នកផ្ទេរប្ដូរមកដាក់រូបអ្នកសិន បើមិនគិតចេះតែសង្កត់សង្កិន ឲ្យគេហិនដោយសារឯងមិនក្រែងខ្លាច ។ ត្រង់នេះមានន័យថា មុននឹងធ្វើទារុណកម្មដល់ជនណាម្នាក់ ត្រូវប្រៀបធៀបកំហុសរបស់ខ្លួនទៅនឹងអ្នកនោះសិន ។

ដូចបានពោលមកហើយ លក្ខណៈរបស់បុគ្គលពាលនិងបុគ្គលជាបណ្ឌិតតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធក្ដី តាមពាក្យរបស់ចាស់បូរាណខ្មែរ ទោះបីពាក្យនេះមិនត្រឹមត្រូវដូចពុទ្ធភាសិតក្ដី ក៏បានផលជាមេរៀនថា បុគ្គលត្រូចសេពគប់បុគ្គលជាបណ្ឌិត កុំសេពគប់បុគ្គលពាល ។ ជាពិសេសទៅទៀត គ្រប់ជំណោះស្រាយជម្លោះក្នុងគ្រួសារក្ដី ក្នុងប្រទេសជាតិក្ដី ក្នុងសហគមន៍អន្តរជាតិក្ដី ត្រូវដោះស្រាយដោយគតិបណ្ឌិត្យ កុំដោះស្រាយតាមគតិពាល ។ ដំណោះស្រាយតាមគតិពាល គឺការប្រើហឹង្សាកាប់សម្លាប់គ្នាជាមធ្យោបាយយកឈ្នះចាញ់គ្នា ព្រះពុទ្ធសំដែងថា មធ្យោ

បាយនេះ មិនអាចបញ្ចប់ការវិវាទគ្នាឡើយ ។ ដំណោះស្រាយតាមគតិបណ្ឌិត គឺដោះស្រាយដោយសន្តិវិធី ឈរលើច្បាប់ទម្លាប់របស់ប្រទេស និងរបស់អង្គការសហប្រជាជាតិ ។ យ៉ាងណាមិញ ប្រទេសកម្ពុជាត្រូវតែដើរតាមគតិបណ្ឌិត ទើបប្រទេសកម្ពុជាបានសុខសន្តិភាព ។៚

❊ ❊

❊